# កម្រងឯកសារអំពី

## ក្សេត្របរិស្ថានដំណាំស្រូវក្នុងប្រទេសកម្ពុជា
## ការកំណត់ក្រុមដីស្រែ
## លក្ខណៈសំខាន់ៗរបស់ពូជស្រូវចំនួន ១០ ពូជ
## វិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវ






# អារម្ភកថា

ឆ្នាំ ១៩៩៥ ជាឆ្នាំដែលប្រទេសកម្ពុជាផលិតស្រូវបានគ្រប់សេចក្តីត្រូវការក្នុងស្រុក និងមានអតិរេកប្រមាណ ៥ សែនតោន បន្ទាប់ពីកសាងប្រទេសចេញពីរបបកម្ពុជាប្រជាធិបតេយ្យ អស់រយៈពេល ១៥ ឆ្នាំ។ ចាប់ពីពេលនោះមក អតិរេកស្រូវបានកើនកាន់តែច្រើនឡើងរហូតដល់ប្រមាណ ៣,៧ លានតោនសម្រាប់ឆ្នាំ ២០១១ ជាមួយនឹងការកើនទិន្នផលពី ១,៦៥ តហត នាឆ្នាំ១៩៩៥ ទៅ២,៩៦ តហត នាឆ្នាំ ២០១០។

យោងតាមកំណើនអតិរេកនេះ និងស្របតាមតម្រូវការអង្ករក្នុងពិភពលោកកាន់តែកើនឡើងជាលំដាប់ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០ **រាជរដ្ឋាភិបាលកម្ពុជា** បានប្រកាសដាក់ឱ្យប្រើប្រាស់នូវ **ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ** ក្នុងគោលបំណងប្រែក្លាយអង្ករឱ្យទៅជា **មាស ស** ពិតប្រាកដរបស់ប្រជាជនកម្ពុជា។ អនុវត្តតាម **ឯកសារគោលនយោបាយ** នេះ និងដោយមានការឯកភាពពី **រាជរដ្ឋាភិបាល** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្សព្វផ្សាយ និងជំរុញឱ្យកសិករប្រើប្រាស់នូវពូជស្រូវចំនួន ១០ ពូជ ក្នុងចំណោមពូជស្រូវចំនួន ៣៨ ពូជ ដែលវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាបានបញ្ចេញជូនកសិករប្រើប្រាស់នាពេលកន្លងមកនេះ។

លទ្ធផលទាំងអស់នេះ បានបញ្ជាក់យ៉ាងច្បាស់ អំពីការទទួលស្គាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាពិសេសរបស់ **រាជរដ្ឋាភិបាល** លើសមិទ្ធផលនៃកិច្ចស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មនៃអង្គភាពជំនាញរបស់ខ្លួន ព្រមទាំងការគាំទ្រ និងចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ផលិតកម្មដំណាំស្រូវនៅកម្ពុជាពីសំណាក់ដៃគូអភិវឌ្ឍន៍នានា ជាពិសេស អូសអេដ (AusAID) វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលនានា។

អនុវត្តតាមតួនាទី និងដើម្បីឱ្យកសិករ ព្រមទាំងអ្នកពាក់ព័ន្ធកាន់តែងាយជ្រើសរើសពូជស្រូវ និងប្រើប្រាស់ពីឱ្យបានត្រឹមត្រូវតាមពេលវេលា និងប្រភេទដីស្រែរបស់ខ្លួន វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានរៀបចំកម្រងឯកសារនេះឡើង។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍នានា ដែលបានឧបត្ថម្ភថវិកា សម្រាប់ការបោះពុម្ពកម្រងឯកសារនេះ ចែកចាយជូនដល់អ្នកពាក់ព័ន្ធទាំងអស់។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១

បណ្ឌិត អ៊ុក ម៉ាការា

នាយក វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

# មាតិកា


| | ទំព័រ |
|---|---|
| ចំណាត់ថ្នាក់ស្ថានភាពដីស្រែក្នុងប្រទេសកម្ពុជា | ១ |
| វិធីសាស្ត្រសាមញ្ញសម្រាប់កសិករធ្វើការកំណត់ក្រុមដីស្រែរបស់ខ្លួន | ៦ |
| ពូជស្រូវ "ជលសារ" | ៨ |
| ពូជស្រូវ "អ៊ីអ៊ែរ៦៦" | ៩ |
| ពូជស្រូវ "សែនពិដោរ" | ១០ |
| ពូជស្រូវ "ផ្ការំដួល" | ១១ |
| ពូជស្រូវ "ផ្ការំដេង" | ១២ |
| ពូជស្រូវ "ផ្ការមៀត" | ១៣ |
| ពូជស្រូវ "ផ្កាច័ន្ទសែនសរ" | ១៤ |
| ពូជស្រូវ "ភិធជ័យ" | ១៥ |
| ពូជស្រូវ "ទា៤" | ១៦ |
| ពូជស្រូវ "ទា៦" | ១៧ |
| វិធីសាស្ត្រសាមញ្ញសម្រាប់កសិករធ្វើការសម្រិតសម្រាំងគ្រាប់ពូជ | ១៨ |



ម.ឯ.ឯ.ក AIDOC

Code: 258-001

Date:

Donated by:

# កាឡី:                ចំណាត់ថ្នាក់ស្ថានភាពដីស្រែក្នុងប្រទេសកម្ពុជា

ការស្គាល់ឲ្យបានច្បាស់អំពីស្ថានភាពដីស្រែ ជួយឲ្យកសិករជ្រើសរើសប្រភេទពូជស្រូវយកមកដាំដុះបានត្រឹមត្រូវ និងទទួលបានទិន្នផលខ្ពស់។ តាមរយៈស្ថានភាពដីជម្រាល របបទឹកស្រោចស្រព និងជម្រៅទឹកដក់ក្នុងស្រែ ដីស្រែក្នុងប្រទេសកម្ពុជា ត្រូវបានបែងចែកជា ៤ ប្រភេទសំខាន់ៗ (រូបភាពទី ១) ដូចខាងក្រោម ៖

រូបភាពទី ១. ការបែងចែកដីស្រែតាមស្ថានភាពដី និងទឹក




## ១. ស្រែខ្ពង់រាប

គឺសំដៅដល់ដីស្រែណា ដែលមានសណ្ឋានជម្រាលខ្លាំង និងមធ្យមហើយ ដែលមិនដក់ទឹក និងមិនមានស្រទាប់បាតនថ្លី។ ដំណាំស្រូវដែលដាំដុះនៅក្នុងប្រព័ន្ធបរិស្ថាននេះ គឺជាស្រូវចម្ការ ដែលមានប្រព័ន្ធឫសចាក់ជ្រៅទៅក្នុងដី ដើម្បីស្រូបយកទឹក និងសារធាតុចិញ្ចឹម។



ស្រូវស្រាល

## ២. ស្រែទំនាបពឹងទឹកភ្លៀង

គឺសំដៅដល់ដីស្រែណា ដែលមានសណ្ឋានជម្រាលខ្សោយ និងមានស្រទាប់បាតនថ្លី បណ្តាលឲ្យមានដក់ទឹកជាប់ជាប្រចាំរហូតដល់រយៈពេល ០១ ខែ ដែលជាទូទៅមានក្នុងខែ តុលា ដោយសារទឹកភ្លៀង របបទឹកទន្លេ និងបឹងធំៗ។ យោងតាមស្ថានភាពនេះ ស្រែដែលឋិតក្នុងតំបន់ទំនាបពឹងទឹកភ្លៀងនេះ ត្រូវបានបែងចែកជាបួនប្រភេទទៀតគឺ៖



ស្រូវកណ្តាល

២.១. *ស្រែលើ* គឺសំដៅដល់ដីស្រែណា ដែលមានទឹកដក់ជម្រៅជាមធ្យមពី ៥ ទៅ ២០ ស.ម ក្នុងរដូវវស្សា ហើយស្រកអស់ពីក្នុងស្រែបន្ទាប់ពីរាំងភ្លៀងក្នុងរយៈពេលប្រហែល ១០ ថ្ងៃ។ តាមស្ថានភាពដី និងទឹកក្នុងស្រែលើនេះ ពូជស្រូវដែលសមស្របបំផុតនោះ គឺជាប្រភេទពូជស្រូវណា ដែលចេញផ្កាមុនពាក់កណ្តាលខែ តុលា ឬចុំក្នុងកំឡុងពេលពីថ្ងៃទី ៥-១៥ ខែ វិច្ឆិកា។ ដូច្នេះ ពូជស្រូវស្រាលមិនប្រកាន់រដូវ ដែលមានអាយុកាលខ្លីជាង ១២០ ថ្ងៃ និងមានកម្ពស់ពី ៥០-១២០ ស.ម ដូចជាពូជស្រូវ សែនពិដោរ ផ្កាខ្ញី និងផ្ការំដួល ជាដើម គឺសមស្របបំផុត។



ស្រូវធ្ងន់